ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.......................សហវ.

# ប្រកាស
# ស្តីពី
# ការណែនាំអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មជាបន្តបន្ទាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone : (+855)23 890 666

# សម្រេច

## ប្រការ ១.- គោលបំណង

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធលើប្រតិបត្តិការធនធានរ៉ែដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការគ្រប់គ្រងប្រមូលពន្ធលើវិស័យធនធានរ៉ែ។

## ប្រការ ២.- គោលដៅ

ប្រកាសនេះ មានគោលដៅកំណត់វិធាននិងនីតិវិធីសម្រាប់គណនាពន្ធលើប្រតិបត្តិការធនធានរ៉ែ ស្របតាមបទប្បញ្ញត្តិក្នុងជំពូកទី ៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧។

## ប្រការ ៣.- វិសាលភាព

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះអ្នកជាប់ពន្ធដែលទទួលបានអាជ្ញាប័ណ្ណ និង/ឬកិច្ចព្រមព្រៀងធ្វើប្រតិបត្តិការធនធានរ៉ែដែលស្ថិតនៅក្នុងដែនអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.- និយមន័យ

ពាក្យទាំងឡាយដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចបានកំណត់នៅក្នុងជំពូកទី ៦ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧។

## ប្រការ ៥.- ពន្ធលើប្រាក់ចំណូល

អនុលោមតាមមាត្រា ១៤៣ នៃច្បាប់ស្តីពីសារពើពន្ធ÷

១- អ្នកជាប់ពន្ធដែលធ្វើប្រតិបត្តិការធនធានរ៉ែ ដូចមានចែងក្នុងមាត្រា ១៤២ នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវជាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ៣០ ភាគរយ នៃប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធ។

២- បន្ថែមលើអត្រាពន្ធដូចមានចែងក្នុងកថាខណ្ឌ ១ នៃប្រការនេះ ប្រសិនបើអ្នកជាប់ពន្ធមានប្រាក់ចំណូលលើសកម្រិត អ្នកជាប់ពន្ធត្រូវជាប់ពន្ធលើប្រាក់ចំណូលលើសកម្រិត តាមអត្រាកំណើនតាមថ្នាក់ដោយផ្អែកលើសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតដូចក្នុងតារាងខាងក្រោម÷

| ថ្នាក់ | សមាមាត្រនៃប្រាក់ចំណូលលើសកម្រិត | | | | អត្រាពន្ធលើប្រាក់ចំណូលលើសកម្រិត |
|---|---|---|---|---|---|
| ១ | | | ដល់ | ១,៣ | ០% |
| ២ | លើសពី | ១,៣ | ដល់ | ១,៦ | ១០% |
| ៣ | លើសពី | ១,៦ | ដល់ | ២ | ២០% |
| ៤ | លើសពី | ២ | | | ៣០% |

សមាមាត្រនៃប្រាក់ចំណូលលើសកម្រិតនៃឆ្នាំជាប់ពន្ធចរន្តណាមួយ គឺជាផលចែកនៃទឹកប្រាក់បូកបង្គរនៃចំណូលនឹងទឹកប្រាក់បូកបង្គរនៃចំណាយ ពីប្រតិបត្តិការធនធានរ៉ែមកទល់នឹងឆ្នាំជាប់ពន្ធចរន្តនោះ។

ការគណនាពន្ធលើប្រាក់ចំណូលលើសកម្រិតត្រូវអនុវត្ត តាមជំហានដូចខាងក្រោម÷

ក- គណនាមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំចរន្ត គុណនឹងផលចែកនៃលម្អៀងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ នឹងសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ

ខ- គណនាពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗ ដោយយកមូលដ្ឋានគិតពន្ធលើប្រាក់ចំណូលលើសកម្រិតតាមថ្នាក់នីមួយៗដែលបានគណនាតាមវាក្យខណ្ឌ ក នៃកថាខណ្ឌនេះ គុណនឹងអត្រាពន្ធសម្រាប់ថ្នាក់នោះ

គ- បូកសរុបប្រាក់ពន្ធលើប្រាក់ចំណូលលើសកម្រិតនៃថ្នាក់នីមួយៗ។

**ឧទាហរណ៍ ៥.១÷**

អ្នកជាប់ពន្ធ មានស្ថានភាពចំណូលចំណាយ ដែលគណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិត (សចលក.) ដូចខាងក្រោម÷

| ឆ្នាំជាប់ពន្ធ | ចំណូល | | ចំណាយ | | ចំណូលសុទ្ធ | សចលក. |
|---|---|---|---|---|---|---|
| | ក្នុងឆ្នាំ | បង្គរ | ក្នុងឆ្នាំ | បង្គរ | | |
| | (ក) | (ខ) | (គ) | (ឃ) | (ង)=(ក)- (គ) | (ច)=(ខ)/(ឃ) |
| ២០២០ | ៩ ០០០ ០០០ | ៩ ០០០ ០០០ | ៨ ០០០ ០០០ | ៨ ០០០ ០០០ | ១ ០០០ ០០០ | ១,១៣ |
| ២០២១ | ១១ ០០០ ០០០ | ២០ ០០០ ០០០ | ៥ ០០០ ០០០ | ១៣ ០០០ ០០០ | ៦ ០០០ ០០០ | ១,៥៤ |
| ២០២២ | ១២ ០០០ ០០០ | ៣២ ០០០ ០០០ | ៤ ០០០ ០០០ | ១៧ ០០០ ០០០ | ៨ ០០០ ០០០ | ១,៨៨ |
| ២០២៣ | ១៤ ០០០ ០០០ | ៤៦ ០០០ ០០០ | ៣ ០០០ ០០០ | ២០ ០០០ ០០០ | ១១ ០០០ ០០០ | ២,៣០ |
| ២០២៤ | ១៥ ០០០ ០០០ | ៦១ ០០០ ០០០ | ២ ០០០ ០០០ | ២២ ០០០ ០០០ | ១៣ ០០០ ០០០ | ២,៧៧ |

**ការគណនាពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិត÷**

**១. ឆ្នាំជាប់ពន្ធ ២០២០÷**

អ្នកជាប់ពន្ធមានចំណូល ៩ ០០០ ០០០ និងចំណាយ ៨ ០០០ ០០០ គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,១៣។ ប្រាក់ចំណូលជាប់ពន្ធគឺ ១ ០០០ ០០០ ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា 0%។

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត

= (១ ០០០ ០០០ x ៣០%) + 0 = <u>៣០០ ០០០</u>

**២. ឆ្នាំជាប់ពន្ធ ២០២១÷**

អ្នកជាប់ពន្ធមានចំណូលបង្គរ ២០ ០០០ ០០០ និងចំណាយបង្គរ ១៣ ០០០ ០០០ គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៥៤។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ ៦ ០០០ ០០០ ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ៦ ០០០ ០០០ x ( (១,៥៤ – ១,៣) / ១,៥៤ ) = ៩៣៥ ០៦៥

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ៩៣៥ ០៦៥ x ១០% = ៩៣ ៥០៦

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត

= (៦ ០០០ ០០០ x ៣០%) + ៩៣ ៥០៦ = **១ ៨៩៣ ៥០៦**

**៣. ឆ្នាំជាប់ពន្ធ ២០២២÷**

អ្នកជាប់ពន្ធមានចំណូលបង្គរ ៣២ ០០០ ០០០ និងចំណាយបង្គរ ១៧ ០០០ ០០០ គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ១,៨៨។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ ៨ ០០០ ០០០ ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០% និង ២០ %។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ៨ ០០០ ០០០ x ( (១,៦ – ១,៣) / ១,៦ ) = ១ ៥០០ ០០០

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ១ ៥០០ ០០០ x ១០% = ១៥០ ០០០

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ៨ ០០០ ០០០ x ( (១,៨៨ – ១,៦) / ១,៨៨ ) = ១ ១៩១ ៤៨៩

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%

= ១ ១៩១ ៤៨៩ x ២០% = ២៣៨ ២៩៨

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត

= (៨ ០០០ ០០០ x ៣០%) + (១៥០ ០០០ + ២៣៨ ២៩៨)

= **២ ៧៨៨ ២៩៨**

**៤. ឆ្នាំជាប់ពន្ធ ២០២៣÷**

អ្នកជាប់ពន្ធមានចំណូលបង្គរ ៤៦ ០០០ ០០០ និងចំណាយបង្គរ ២០ ០០០ ០០០ គណនាជាសមាមាត្រនៃប្រាក់ចំណូលលើសកម្រិតស្មើនឹង ២,៣០។ ដូចនេះ ប្រាក់ចំណូលជាប់ពន្ធ ១១ ០០០ ០០០ ត្រូវជាប់ពន្ធលើប្រាក់ចំណូល និងពន្ធលើប្រាក់ចំណូលលើសកម្រិតតាមអត្រា ១០%, ២០%, និង ៣០%។

មូលដ្ឋានគិត **ពចលក.** តាមអត្រា ១០% = ១១ ០០០ ០០០ x ( (១,៦ – ១,៣) / ១,៦ ) = ២ ០៦២ ៥០០

**ពចលក.** តាមអត្រា ១០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ១០%

= ២ ០៦២ ៥០០ x ១០% = ២០៦ ២៥០

មូលដ្ឋានគិត **ពចលក.** តាមអត្រា ២០% = ១១ ០០០ ០០០ x ( (២ – ១,៦) / ២ ) = ២ ២០០ ០០០

**ពចលក.** តាមអត្រា ២០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. ២០%

= ២ ២០០ ០០០ x ២០% = ៤៤០ ០០០

មូលដ្ឋានគិត **ពចលក.** តាមអត្រា ៣០% = ១១ ០០០ ០០០ x ( (២,៣០ – ២) / ២,៣០ ) = ១ ៤៣៤ ៧៨៣

**ពចលក.** តាមអត្រា ៣០% = មូលដ្ឋានគិត ពចលក. x អត្រា ពចលក. តាមអត្រា ៣០%

= ១ ៤៣៤ ៧៨៣ x ៣០% = ៤៣០ ៤៣៥

ពន្ធលើប្រាក់ចំណូលត្រូវបង់សរុប = ពន្ធលើប្រាក់ចំណូល + ពន្ធលើប្រាក់ចំណូលលើសកម្រិត

= (១១ ០០០ ០០០ x ៣០%) + (២០៦ ២៥០ + ៤៤០ ០០០ + ៤៣០ ៤៣៥) = **៤ ៣៧៦ ៦៨៥**

## ប្រការ ៦.- ចំណាយការប្រាក់

សម្រាប់គោលដៅនៃពន្ធលើប្រតិបត្តិការធនធានរ៉ែ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងចំណាយការប្រាក់ត្រឹមតែចំនួនដែលគណនាតាមវិធានសមាមាត្រនៃបំណុល ៣ ធៀបនឹង ដើមទុន ១ ទោះបីអ្នកជាប់ពន្ធខ្ចីបុលប្រាក់ដើម្បីប្រកបអាជីវកម្មរបស់ខ្លួនក្នុងកម្រិតណាក៏ដោយ។

សម្រាប់គោលដៅនៃប្រកាសនេះ÷

ក- ពាក្យ "បំណុល" សំដៅដល់ ចំនួនទឹកប្រាក់សរុបដែលអ្នកជាប់ពន្ធជំពាក់ឬត្រូវបង់សង រួមទាំងប្រាក់ខ្ចី ឧបករណ៍ហិរញ្ញវត្ថុ ភតិសន្យាហិរញ្ញវត្ថុ ឬឧបករណ៍ហិរញ្ញវត្ថុណាមួយដែលបង្កើតជាការប្រាក់ ការបញ្ចុះតម្លៃ និងបន្ទុកហិរញ្ញវត្ថុដទៃទៀត ដែលអាចកាត់កងបានដើម្បីគណនាប្រាក់ចំណូលជាប់ពន្ធ

ខ- ពាក្យ"ដើមទុន" រួមមាន មូលធនភាគហ៊ុនគ្រប់ប្រភេទ តម្លៃលើសនៃការលក់ប័ណ្ណភាគហ៊ុន មូលធនបម្រុងតាមច្បាប់ លម្អៀងលើសនៃការវាយតម្លៃឡើងវិញនូវទ្រព្យសកម្ម និងប្រាក់ចំណូលរក្សាទុក។

**ឧទាហរណ៍ ៦.១÷**

អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដើមទុនចំនួន ២០ ០០០ ០០០។ ដោយខ្វះដើមទុន អ្នកជាប់ពន្ធបានខ្ចីប្រាក់ចំនួន ៨០ ០០០ ០០០ ក្នុងអត្រាការប្រាក់ ៥ ភាគរយក្នុងមួយឆ្នាំ។ ដូចនេះ ចំណាយការប្រាក់ដែលអ្នកជាប់ពន្ធត្រូវបង់ឱ្យម្ចាស់បំណុលក្នុងមួយឆ្នាំ ស្មើនឹង ៨០ ០០០ ០០០x ៥% = ៤ ០០០ ០០០ ។

ក្នុងការគណនាប្រាក់ចំណូលជាប់ពន្ធតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធមិនអាចកាត់កងចំណាយការប្រាក់ដែលបង់ឱ្យម្ចាស់បំណុលទាំងស្រុងចំនួន ៤ ០០០ ០០០ បានទេ។ អ្នកជាប់ពន្ធត្រូវគណនាការប្រាក់ដែលអនុញ្ញាតឱ្យកាត់កងតាមវិធានសមាមាត្របំណុល ៣ ធៀបនឹងដើមទុន ១ ដូចខាងក្រោម÷

មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង = ដើមទុនរបស់អ្នកជាប់ពន្ធ x ៣

= ២០ ០០០ ០០០x ៣

= ៦០ ០០០ ០០០

ចំនួនការប្រាក់ដែលអនុញ្ញាតឱ្យកាត់កង = មូលដ្ឋានគិតការប្រាក់ដើម្បីកាត់កង x អត្រាការប្រាក់

= ៦០ ០០០ ០០០x ៥%

= ៣ ០០០ ០០០

ដោយឡែកចំពោះពន្ធកាត់ទុកដែលមានចែងក្នុងមាត្រា ២៥ថ្មី ឬមាត្រា ២៦ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ត្រូវអនុវត្តលើចំណាយការប្រាក់ជាក់ស្តែងចំនួន ៤ ០០០ ០០០ ដែលបានបង់ឱ្យម្ចាស់បំណុល។

## ប្រការ ៧.- ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន និងចំណាយស្តារបរិស្ថានជាក់ស្តែង

អនុលោមតាមមាត្រា ១៤៦ នៃច្បាប់ស្តីពីសារពើពន្ធ ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន និងចំណាយស្តារបរិស្ថានជាក់ស្តែង ត្រូវបានកំណត់ដូចតទៅ÷

១- អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យបង្កើតគណនីប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន ដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ មុនពេលការស្តារបរិស្ថានជាក់ស្តែងបានកើតឡើង។ ប្រាក់បម្រុងនេះត្រូវបានអនុញ្ញាតឱ្យធ្វើសំវិធានធនសម្រាប់ចំណាយស្តារបរិស្ថាន និងត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលក្នុងឆ្នាំជាប់ពន្ធ។ ក្នុងករណីអ្នកជាប់ពន្ធគ្មានគម្រោងស្តារបរិស្ថានដែលបានយល់ព្រមដោយស្ថាប័នទេ ការកាត់កងតាមប្រការនេះមិនត្រូវបានអនុញ្ញាតទេ។

២- ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន ត្រូវបានគណនាដោយផ្អែកទៅតាមចំណាយសរុបដែលបានយល់ព្រមសម្រាប់គម្រោងស្តារបរិស្ថាន។ ប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថានក្នុងឆ្នាំនីមួយៗ និងឆ្នាំដែលប្រាក់បម្រុងត្រូវបានអនុញ្ញាតឱ្យចាប់ផ្តើមកាត់កង ត្រូវកំណត់តាមគម្រោងស្តារបរិស្ថាន។

៣- ប្រសិនបើចំណាយសរុបនៃការស្តារបរិស្ថានជាក់ស្តែង ដែលបានធ្វើឡើងដោយអ្នកជាប់ពន្ធមានចំនួនលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន ចំនួនលើសនោះត្រូវបានអនុញ្ញាតឱ្យកាត់កងពីប្រាក់ចំណូលជាប់ពន្ធប្រចាំឆ្នាំ។

៤- ប្រសិនបើចំណាយសរុបនៃការស្តារបរិស្ថានជាក់ស្តែងដែលបានធ្វើឡើងដោយអ្នកជាប់ពន្ធ មានចំនួនតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុងសម្រាប់ចំណាយស្តារបរិស្ថាន ចំនួនលម្អៀងនោះត្រូវគិតបញ្ចូលក្នុង ប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការស្តារបរិស្ថាននោះបានបញ្ចប់។

**ឧទាហរណ៍ ៧.១÷ ករណីចំណាយសរុបនៃការស្តារបរិស្ថានជាក់ស្តែងលើសពីចំនួនសរុបនៃទឹកប្រាក់បម្រុង**

អ្នកជាប់ពន្ធ ធ្វើប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាប័ណ្ណមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់ស្តារបរិស្ថានដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៥០០ ០០០។ ចំនួនទឹកប្រាក់បម្រុងសម្រាប់ស្តារបរិស្ថាននេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី ១ រហូតដល់ឆ្នាំជាប់ពន្ធទី ៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ១០០ ០០០។ ក្នុងការស្តារបរិស្ថានជាក់ស្តែង អ្នកជាប់ពន្ធបានចំណាយទឹកប្រាក់សរុបចំនួន ៥៤០ ០០០ ដែលលើសពីទឹកប្រាក់បម្រុងចំនួន ៤០ ០០០។ ទឹកប្រាក់លម្អៀងនេះត្រូវបានអនុញ្ញាតជាចំណាយកាត់កងបន្ថែមនៅក្នុងឆ្នាំជាប់ពន្ធ។

**ឧទាហរណ៍ ៧.២÷ ករណីចំណាយសរុបនៃការស្តារបរិស្ថានជាក់ស្តែងតិចជាងចំនួនសរុបនៃទឹកប្រាក់បម្រុង**

អ្នកជាប់ពន្ធ ធ្វើប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាប័ណ្ណមួយ ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មចំនួន ៥ឆ្នាំ។ ទឹកប្រាក់បម្រុងសម្រាប់ស្តារបរិស្ថានដែលបានយល់ព្រមដោយស្ថាប័នមានចំនួន ៥០០ ០០០។ ចំនួនទឹកប្រាក់បម្រុងសម្រាប់ស្តារបរិស្ថាននេះ ត្រូវបានអនុញ្ញាតឱ្យកាត់កងចាប់ពីឆ្នាំជាប់ពន្ធទី ១ រហូតដល់ឆ្នាំជាប់ពន្ធទី ៥ ដោយក្នុងមួយឆ្នាំៗមានចំនួន ១០០ ០០០។ នៅពេលការស្តារបរិស្ថានត្រូវបានបញ្ចប់ អ្នកជាប់ពន្ធ បានចំណាយលើការស្តារបរិស្ថានជាក់ស្តែងចំនួន ៤៥០ ០០០ ដែលតិចជាងទឹកប្រាក់បម្រុងចំនួន ៥០ ០០០។ ទឹកប្រាក់លម្អៀងនេះត្រូវគិតបញ្ចូលទៅក្នុងប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំជាប់ពន្ធដែលការស្តារបរិស្ថាននោះបានបញ្ចប់។

**ប្រការ ៨.‐ វិធីរំលស់**

វិធីរំលស់សម្រាប់ប្រតិបត្តិការធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម÷

១- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមមាត្រា ១៤៨ នៃច្បាប់ស្តីពីសារពើពន្ធ។ រំលស់ស្មើភាគសម្រាប់ប្រតិបត្តិការធនធានរ៉ែ ត្រូវបានកំណត់ដូចខាងក្រោម÷

ក- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនានិងចំណាយស្វែងរុករក តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៥ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ខ- អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយអភិវឌ្ឍន៍ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មរបស់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ឬ ៧ឆ្នាំ សម្រាប់ប្រតិបត្តិការធនធានរ៉ែ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

គ- ក្នុងករណីអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មក្រោមគម្រោងអភិវឌ្ឍន៍ត្រូវបានកែប្រែ អ្នកជាប់ពន្ធត្រូវកែតម្រូវការធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលនៅសល់តាមអាយុកាលរំពឹងទុកដែលកែប្រែថ្មី ប៉ុន្តែមិនត្រូវលើសពីអាយុកាលរំលស់តាមវាក្យខណ្ឌ ក និងវាក្យខណ្ឌ ខ នៃកថាខណ្ឌនេះឡើយ

ឃ- ក្នុងករណីអ្នកជាប់ពន្ធមានគម្រោងអភិវឌ្ឍន៍ដែលមានរយៈពេលតិចជាងមួយឆ្នាំ ចំណាយអភិវឌ្ឍន៍នេះអាចបញ្ចូលទៅធ្វើរំលស់ក្នុងចំណាយបុរេសនា និងចំណាយស្វែងរុករក

ង- អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មត្រូវកំណត់ដោយអ្នកជាប់ពន្ធ ដែលមានការយល់ព្រមពីស្ថាប័នដូចដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ។

២- ចំពោះទ្រព្យរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានទិញឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ទ្រព្យរូបីទាំងនោះតាមវាក្យខណ្ឌ ក ដល់វាក្យខណ្ឌ ឃ នៃកថាខណ្ឌ ១ នៃមាត្រា ១៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

៣-ចំពោះទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ អ្នកជាប់ពន្ធត្រូវធ្វើរំលស់តាមមាត្រា ១៤ នៃច្បាប់ស្តីពីសារពើពន្ធ។

**ឧទាហរណ៍ ៨.១÷ ករណីកើនឡើងអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម**

អ្នកជាប់ពន្ធ ធ្វើប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាប័ណ្ណមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៤ឆ្នាំ។ នៅដើមឆ្នាំទី ៤ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួល អាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មរហូតដល់រយៈពេល ៥ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ៤០០ | ១០០ | ១០០ | ១០០ | ៥០ | ៥០ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២.៥% | ១២.៥% |
| អភិវឌ្ឍន៍ | ៨០០ | ២០០ | ២០០ | ២០០ | ១០០ | ១០០ |
| | ១០០% | ២៥% | ២៥% | ២៥% | ១២.៥% | ១២.៥% |

**ឧទាហរណ៍ ៨.២÷ ករណីថយចុះអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម**

អ្នកជាប់ពន្ធ ធ្វើប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាប័ណ្ណមួយ ដែលអាយុកាលរំពឹងទុកដំបូងនៃផលិតកម្មពាណិជ្ជកម្មមានរយៈពេល ៥ឆ្នាំ។ នៅដើមឆ្នាំទី ៣ អ្នកជាប់ពន្ធបានសម្រេចចិត្តធ្វើការកែសម្រួល អាយុកាលរំពឹងទុកនៃមធ្យោបាយផលិតកម្មពាណិជ្ជកម្មថយចុះមកត្រឹម ៤ឆ្នាំ។

| ចំណាយ | សរុប | ឆ្នាំទី ១ | ឆ្នាំទី ២ | ឆ្នាំទី ៣ | ឆ្នាំទី ៤ | ឆ្នាំទី ៥ |
|---|---|---|---|---|---|---|
| ស្វែងរុករក | ៤០០ | ៨០ | ៨០ | ១២០ | ១២០ | 0 |
| | ១០០% | ២០% | ២០% | ៣០% | ៣០% | 0% |
| អភិវឌ្ឍន៍ | ៨០០ | ១៦០ | ១៦០ | ២៤០ | ២៤០ | 0 |
| | ១០០% | ២០% | ២០% | ៣០% | ៣០% | 0% |

**ប្រការ ៩.- ពេលចាប់ផ្តើមធ្វើរំលស់**

ពេលចាប់ផ្តើមធ្វើរំលស់ ត្រូវបានកំណត់ដូចខាងក្រោម ÷

១- អ្នកជាប់ពន្ធ ត្រូវចាប់ផ្តើមធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ ដែលបានកើតឡើងមុនពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូង នៅដំណាច់ឆ្នាំជាប់ពន្ធដែលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ។

២- ក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មដំបូងក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ ប្រសិនបើអ្នកជាប់ពន្ធធ្វើបុរេសនា ឬស្វែងរុករកឬសាងសង់បន្តនូវមធ្យោបាយផលិតកម្មដទៃទៀតក្រោមគម្រោងអភិវឌ្ឍន៍ក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមពេលដូចខាងក្រោម÷

- ក- នៅដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ចំពោះចំណាយបុរេសនា ឬចំណាយស្វែងរុករក ទៅតាមលំដាប់ឆ្នាំដែលចំណាយនោះបានកើតឡើង
- ខ- នៅដំណាច់ឆ្នាំជាប់ពន្ធដែលមធ្យោបាយផលិតកម្មនីមួយៗត្រូវបានដាក់ឱ្យប្រើប្រាស់ ចំពោះចំណាយអភិវឌ្ឍន៍។

៣- ចំពោះទ្រព្យរូបី និងទ្រព្យអរូបី ក្រៅពីចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ដែលបានទិញ ឬបានបង្កើតក្រោយពេលចាប់ផ្តើមធ្វើផលិតកម្មពាណិជ្ជកម្មក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ អ្នកជាប់ពន្ធត្រូវធ្វើរំលស់នៅដំណាច់ឆ្នាំជាប់ពន្ធដែលទ្រព្យទាំងនោះត្រូវបានដាក់ឱ្យប្រើប្រាស់។

៤- ប្រសិនបើប្រតិបត្តិការធនធានរ៉ែត្រូវបានបញ្ចប់ក្នុងឆ្នាំជាប់ពន្ធណាមួយ អ្នកជាប់ពន្ធត្រូវបានអនុញ្ញាតឱ្យកាត់កងជាចំណាយនូវតម្លៃទ្រព្យសកម្មដែលនៅសេសសល់ទាំងអស់ រួមបញ្ចូលទាំងចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ នៅក្នុងឆ្នាំជាប់ពន្ធ។

រំលស់ត្រូវធ្វើដាច់ដោយឡែកៗពីគ្នា សម្រាប់មធ្យោបាយផលិតកម្មនីមួយៗក្រោមគម្រោងអភិវឌ្ឍន៍ ស្របតាមកថាខណ្ឌ ១ នៃប្រការ ៨ នៃប្រកាសនេះ ហើយត្រូវបូកសរុបបញ្ចូលគ្នាសម្រាប់កាត់កងក្នុងឆ្នាំជាប់ពន្ធ។

**ឧទាហរណ៍ ៩.១÷ ករណីមានមធ្យោបាយផលិតកម្មច្រើន**

អ្នកជាប់ពន្ធធ្វើប្រតិបត្តិការធនធានរ៉ែក្នុងតំបន់ទទួលអាជ្ញាប័ណ្ណមួយដែលមានមធ្យោបាយផលិតកម្មចំនួន ២ ក្នុងគម្រោងអភិវឌ្ឍន៍តែមួយ ដូចខាងក្រោម÷

- មធ្យោបាយផលិតកម្មទី១ មានអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម រយៈពេល ៦ឆ្នាំ និងបានចំណាយស្វែងរុករកមានចំនួន ៥ ០០០ ០០០ និងចំណាយអភិវឌ្ឍន៍ចំនួន ១២ ០០០ ០០០
- មធ្យោបាយផលិតកម្មទី២ បានចាប់ផ្តើមនៅឆ្នាំទី៤ដែលមានអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម រយៈពេល ៧ឆ្នាំ និងចាប់ផ្តើមផលិតកម្មពាណិជ្ជកម្មនៅឆ្នាំទី ៥។ ចំណាយស្វែងរុករកមានចំនួន ១០ ០០០ ០០០ និងចំណាយអភិវឌ្ឍន៍ចំនួន ២១ ០០០ ០០០។

| ចំណាយ | រយៈពេលនៃការធ្វើរំលស់ (ឆ្នាំ) | អាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម | សរុប (លាន) | ឆ្នាំទី | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| | **គម្រោងអភិវឌ្ឍន៍ទី១** | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៦ | ៥ | ១ | ១ | ១ | ១ | ១ | | | | | | | |
| អភិវឌ្ឍន៍ | ៦ | | ១២ | ២ | ២ | ២ | ២ | ២ | ២ | | | | | | |
| | **គម្រោងអភិវឌ្ឍន៍ទី២** | | | | | | | | | | | | | | |
| ស្វែងរុករក | ៥ | ៧ | ១០ | | | | ២ | ២ | ២ | ២ | ២ | | | | |
| អភិវឌ្ឍន៍ | ៧ | | ២១ | | | | | ៣ | ៣ | ៣ | ៣ | ៣ | ៣ | ៣ | |
| សរុប | | | | ៣ | ៣ | ៣ | ៥ | ៨ | ៧ | ៥ | ៥ | ៣ | ៣ | ៣ | |

**ប្រការ ១០.- ការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ**

ក្នុងករណីមានការផ្ទេរមួយផ្នែកឬទាំងស្រុងនៃអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ តាមរូបភាពលក់ទិញ ដោះដូរ ឬធ្វើអំណោយ អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ និងបុគ្គលជាអ្នកទទួលបន្ត ត្រូវអនុវត្តដូចខាងក្រោម÷

១- អ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ត្រូវកត់ត្រាចំណូលដែលទទួលបានពីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ ជាចំណូលពីប្រតិបត្តិការធនធានរ៉ែ ដែលជាកម្មវត្ថុនៃពន្ធលើប្រាក់ចំណូលស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសារពើពន្ធ។

២- បុគ្គលជាអ្នកទទួលបន្តត្រូវ÷

ក- បន្តអនុវត្តកាតព្វកិច្ចសារពើពន្ធពីអ្នកជាប់ពន្ធដែលជាអ្នកផ្ទេរ ចំពោះអត្ថប្រយោជន៍ដែលជាសិទ្ធិ ឬចំណែកដែលបានទទួល

ខ- បន្តធ្វើរំលស់ទ្រព្យរូបី ទ្រព្យអរូបី ចំណាយបុរេសនា ចំណាយស្វែងរុករក និងចំណាយអភិវឌ្ឍន៍ តាមវិធាន និងនីតិវិធី និងមូលដ្ឋានដែលអ្នកជាប់ពន្ធបានធ្វើរំលស់កន្លងមក

គ- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ មានតម្លៃលើសពីតម្លៃពិតគណនេយ្យ តម្លៃលម្អៀងត្រូវបានចាត់ទុកជាមូលនិធិពាណិជ្ជកម្ម។ បុគ្គលជាអ្នកទទួលបន្ត ត្រូវធ្វើរំលស់មូលនិធិពាណិជ្ជកម្មនេះ តាមវិធីរំលស់ស្មើភាគតាមអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្ម ដែលនៅសល់ ឬ ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង

ឃ- ក្នុងករណីការផ្ទេរអត្ថប្រយោជន៍ក្នុងកិច្ចព្រមព្រៀងធនធានរ៉ែ មានតម្លៃតិចជាងតម្លៃពិតគណនេយ្យ ត្រូវកត់ត្រាតម្លៃលម្អៀងជាចំណូលសម្រាប់ឆ្នាំបន្តបន្ទាប់ ដោយបែងចែកតាមសមាមាត្រនៃអាយុកាលរំពឹងទុកនៃផលិតកម្មពាណិជ្ជកម្មដែលនៅសល់ ឬ ៧ឆ្នាំ ដោយជ្រើសរើសយកជម្រើសណាមួយដែលតិចជាង។

## ប្រការ ១១.- កំហិតលើការកាត់កង

ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ នៅក្នុងតំបន់ទទួលអាជ្ញាប័ណ្ណណាមួយ សម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានអនុញ្ញាតឱ្យកាត់កងតែពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែ ក្នុងតំបន់ទទួលអាជ្ញាប័ណ្ណនៃឆ្នាំជាប់ពន្ធនោះប៉ុណ្ណោះ។

ចំណាយដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទទួលអាជ្ញាប័ណ្ណណាមួយ មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទទួលអាជ្ញាប័ណ្ណដទៃទៀតទេ ហើយក៏មិនអាចកាត់កងពីប្រាក់ចំណូលដុលសរុបពីប្រភពផ្សេងទៀតក្រៅពីប្រតិបត្តិការធនធានរ៉ែឡើយ។

## ប្រការ ១២.- ការយោងការខាតបង់

ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធណាមួយ ចំណាយសរុបដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ លើសពីចំណូលដុលសរុបដែលនាំឱ្យមានលទ្ធផលខាតបង់ ការខាតបង់ត្រូវបានអនុញ្ញាតឱ្យយោងទៅកាត់កងពីប្រាក់ចំណូលជាប់ពន្ធ ដែលសម្រេចបានក្នុងឆ្នាំជាប់ពន្ធបន្ទាប់។

ប្រសិនបើប្រាក់ចំណូលជាប់ពន្ធនៃឆ្នាំជាប់ពន្ធបន្ទាប់ មិនគ្រប់គ្រាន់សម្រាប់កាត់កងការយោងខាតជាស្ថាពរទេ ចំណែកនៃការខាតបង់ដែលនៅសេសសល់ត្រូវបានអនុញ្ញាតឱ្យយោងទៅមុខ រហូតដល់ ៥ឆ្នាំ ដោយមិនគិតថាអ្នកជាប់ពន្ធមានប្រាក់ចំណូលជាប់ពន្ធ ឬខាតបង់នោះទេ។ ប្រសិនបើក្នុងរយៈពេល ៥ឆ្នាំ ចំណែកនៃការយោងការខាតបង់មិនអាចកាត់កងអស់ជាស្ថាពរទេ ចំណែកខាតបង់ដែលនៅសេសសល់នោះមិនត្រូវបានអនុញ្ញាតឱ្យកាត់កងទៀតឡើយ។ ក្នុងករណីដែលមានការខាតបង់លើសពីមួយឆ្នាំ ការយោងការខាតបង់ត្រូវអនុវត្តតាមលំដាប់ឆ្នាំដែលការខាតបង់ទាំងឡាយបានកើតឡើង។

ការខាតបង់ដែលកើតមានឡើងនៅក្នុងតំបន់ទទួលអាជ្ញាប័ណ្ណណាមួយ មិនអាចយោងយកទៅកាត់កងក្នុងតំបន់ទទួលអាជ្ញាប័ណ្ណដទៃទៀតឡើយ។

**ឧទាហរណ៍ ១២.១÷**

- ក្នុងឆ្នាំជាប់ពន្ធទី ១ អ្នកជាប់ពន្ធមានលទ្ធផលខាត ចំនួន ២ ០០០ ០០០
- ក្នុងឆ្នាំជាប់ពន្ធទី ២ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ១០០ ០០០។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ១០០ ០០០ នេះ មកកាត់កងជាមួយការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី ១។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី ១ ចំនួន ១ ៩០០ ០០០ ដើម្បីយោងទៅឆ្នាំបន្ទាប់

- ក្នុងឆ្នាំជាប់ពន្ធទី ៣ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៣០០ ០០០។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៣០០ ០០០ នេះ មកកាត់កងជាមួយការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី ១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ចំនួន១ ៦០០ ០០០
- ក្នុងឆ្នាំជាប់ពន្ធទី ៤ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៥០០ ០០០។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៥០០ ០០០ នេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ចំនួន ១ ១០០ ០០០
- ក្នុងឆ្នាំជាប់ពន្ធទី ៥ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ៤០០ ០០០។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ៤០០ ០០០ នេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ចំនួន ៧០០ ០០០
- ក្នុងឆ្នាំជាប់ពន្ធទី ៦ អ្នកជាប់ពន្ធមានលទ្ធផលចំណូលសុទ្ធ (ចំណេញ) ចំនួន ២០០ ០០០។ អ្នកជាប់ពន្ធអាចយកទឹកប្រាក់ ២០០ ០០០ នេះ មកកាត់កងជាមួយការយោងខាតក្នុងឆ្នាំជាប់ពន្ធទី ១ ដែលនៅសល់។ ដូចនេះ អ្នកជាប់ពន្ធនៅសល់ការខាតបង់ក្នុងឆ្នាំជាប់ពន្ធទី ១ ចំនួន ៥០០ ០០០ ដែលការខាតបង់នេះមិនអាចយោងទៅឆ្នាំបន្ទាប់បានឡើយ។

**ប្រការ ១៣.- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល**

យោងតាមមាត្រា ២៨ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ អ្នកជាប់ពន្ធមានកាតព្វកិច្ចបង់ប្រាក់រំដោះប្រចាំខែសម្រាប់ពន្ធលើប្រាក់ចំណូលតាមអត្រា ១ភាគរយ នៃផលរបរដែលសម្រេចបានក្នុងខែមុន ដោយគិតរួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែម។ ប្រាក់រំដោះនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

នៅពេលដាក់លិខិតប្រកាសបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ប្រសិនបើប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលបានបង់ក្នុងឆ្នាំជាប់ពន្ធណាមួយ ច្រើនជាងបំណុលពន្ធលើប្រាក់ចំណូល ចំនួនលម្អៀងត្រូវបានអនុញ្ញាតជាឥណទានសម្រាប់ប្រើប្រាស់ជាប្រាក់រំដោះពន្ធលើប្រាក់ចំណូលសម្រាប់ខែបន្តបន្ទាប់ ក្រោយពីការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជាប់ពន្ធនោះ។

នៅពេលបញ្ចប់ប្រតិបត្តិការធនធានរ៉ែ ប្រសិនបើមាននៅសល់ឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូលអ្នកជាប់ពន្ធអាចធ្វើការស្នើសុំទៅរដ្ឋបាលសារពើពន្ធ ឱ្យបង្វិលសងនូវឥណទានប្រាក់រំដោះពន្ធលើប្រាក់ចំណូលដែលនៅសល់នោះ។

**ប្រការ ១៤.- កាតព្វកិច្ចសារពើពន្ធ**

អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធ ប្រចាំខែ ប្រចាំឆ្នាំ ដាច់ដោយឡែកពីគ្នា ជូនរដ្ឋបាលសារពើពន្ធ ទៅតាមការកំណត់នៃច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ។

ប្រតិបត្តិករដែលជាតំណាងអ្នកជាប់ពន្ធទាំងអស់ក្នុងតំបន់ទទួលអាជ្ញាប័ណ្ណ ត្រូវផ្តល់របាយការណ៍និងឯកសារនានានៃប្រតិបត្តិការអាជីវកម្មក្នុងតំបន់ទទួលអាជ្ញាប័ណ្ណតាមការតម្រូវរបស់រដ្ឋបាលសារពើពន្ធ។

**ប្រការ ១៥.- ការប្រើប្រាស់ភាសាសម្រាប់ការកាន់កាប់បញ្ជីគណនេយ្យ**

អ្នកជាប់ពន្ធអាចស្នើសុំការអនុញ្ញាតពីរដ្ឋបាលសារពើពន្ធ ដើម្បីប្រើប្រាស់ភាសាអង់គ្លេស និងប្រើប្រាស់រូបិយប័ណ្ណជាប្រាក់ដុល្លារសហរដ្ឋអាមេរិកសម្រាប់កត់ត្រាបញ្ជីកាគណនេយ្យ របាយការណ៍ និងឯកសារនានាដែលទាក់ទិននឹងប្រតិបត្តិការធនធានរ៉ែ។

**ប្រការ ១៦.- អវសានប្បញ្ញត្តិ**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ១៧.- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកឬអគ្គនាយកនៃអគ្គនាយកដ្ឋាននានាចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់សហគ្រាសដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ